# ផែនការសកម្មភាពបណ្តាញសហគមន៍នេសាទ

# (២០២៥-២០២៨)

ខេត្តកោះកុង

រៀបចំឡើងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥

**មាតិកា**


១. សេចក្តីផ្តើម ........ 2

២. គោលបំណង ........ 2

៣. តួនាទី និងភារកិច្ចបណ្តាញ ........ 3

៤. ផែនការសកម្មភាពបណ្តាញសហគមន៍នេសាទ ........ 4

  ៤. ១ ផែនការសកម្មភាពបណ្តាញសហគមន៍នេសាទសម្រាប់៣ឆ្នាំ ........ 4

  ៤. ២ ផែនការសកម្មភាពបណ្តាញសហគមន៍នេសាទប្រចាំឆ្នាំ ........ 8

៥. ផែនការកៀរគរធនធាន និងថវិកា ........ 12

៦. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ........ 12

## ១. សេចក្តីផ្តើម

បណ្តាញសហគមន៍នេសាទ ភាពជាដៃគូរវាងសហគមន៍នេសាទ ដែលជាយន្តការជួយសម្របសម្រួលដល់សហគមន៍នេសាទជាសមាជិក។ បណ្តាញសហគមន៍នេសាទ ត្រូវបានរៀបចំឡើងស្របតាមសេចក្តីព្រាងសេចក្តីណែនាំបណ្តាញសហគមន៍នេសាទនេះ ដោយរៀបចំឡើងក្នុងគោលបំណង ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពរបស់សមាជិកបណ្តាញសហគមន៍នេសាទ ក្នុងការគាំទ្រដល់សហគមន៍នេសាទចូលរួមគ្រប់គ្រងធនធានជលផល និងកែលម្អមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ និងសមាជិកសហគមន៍នេសាទ។ បណ្តាញសហគមន៍នេសាទកើតឡើងពីការបោះឆ្នោត ដោយសេរី យុត្តិធម៌ និងត្រឹមត្រូវ ដែលបានរៀបចំឡើងកាលពីដើមខែមេសា ឆ្នាំ២០២៥។ ការរៀបចំបណ្តាញសហគមន៍នេះគឺស្ថិតក្នុងដំណាក់កាលសាកល្បង ដើម្បីប្រមូលធាតុចូលសម្រាប់រៀបចំលិខិតគតិយុត្តិពាក់ព័ន្ធបណ្តាញសហគមន៍នេសាទ។ ក្នុងស្ថានភាពនេះបណ្តាញសហគមន៍នេសាទ បានរៀបចំផែនការរួមមួយ និងយកចិត្តទុកដាក់លើបញ្ហាអាទិភាពសំខាន់ៗ ដើម្បីអោយបណ្តាញដំណើរការបានប្រសើរដូចជា ការកសាងសមត្ថភាពសម្រាប់គណៈកម្មការបណ្តាញ ពង្រឹងការគ្រប់គ្រង ពង្រឹងកិច្ចសហការ និងការសម្របសម្រួល ការចងក្រងព័ត៌មាន ព្រមទាំងមធ្យោបាយ និងសំភារៈចាំបាច់ផ្សេងៗ សម្រាប់សម្រួលដល់តម្រូវការបណ្តាញ។

ផែនការបណ្តាញសហគមន៍នេសាទត្រូវបានរៀបចំឡើងសម្រាប់រយៈពេលបីឆ្នាំចាប់ពីខែកក្កដា ឆ្នាំ២០០៥ ដល់ខែមិថុនា ឆ្នាំ២០២៨ ដោយមានការចូលរួមពីគណៈកម្មការគ្រប់គ្រង និងសមាជិកបណ្តាញសហគមន៍នេសាទមកពីសហគន៍ថ្មស តាមាយ កណ្តោល ជ្រោយស្វាយ កោះខ្យង បាក់អង្រុត ព្រះអង្គកែវ សាលាម្នាង និងសហគមន៍នេសាទអភិវឌ្ឍន៍ទឹកប៉ោងអូរជ្រៅ សហការជាមួយអង្គការដៃគូ អាជ្ញាធរស្រុក មន្ទីរបរិស្ថាន និងមន្ត្រីតំបន់ការពារ និងរដ្ឋបាលជលផលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ២. គោលបំណង

- ជម្រុញការគ្រប់គ្រងធនធានជលផលរបស់សហគមន៍នេសាទជាសមាជិកបណ្តាញ ក្នុងការចូលរួមគ្រប់គ្រងធនធានជលផលអោយមាននិរន្តរភាព
- លើកកម្ពស់ការចូលរួម និងការសហការជាមួយប្រជានេសាទ អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធក្នុងការចូលរួមគ្រប់គ្រង ការពារ អភិរក្ស និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព
- លើកកម្ពស់ការកៀរគរធនធាន និងសមត្ថភាពសម្រាប់បណ្តាញ និងសហគមន៍នេសាទជាសមាជិក
- លើកកម្ពស់ប្រសិទ្ធិភាពការគ្រប់គ្រង និងការទទួលខុសត្រូវសម្រាប់គណៈកម្មការបណ្តាញសហគមន៍នេសាទ
- បង្កើនប្រសិទ្ធភាព ក្នុងការទំនាក់ទំនង ចែករំលែក និងការផ្សព្វផ្សាយ សម្រាប់បណ្តាញសហគមន៍នេសាទ។

## ៣. តួនាទី និងភារកិច្ចបណ្តាញ

បណ្តាញសហគមន៍នេសាទ ដឹកនាំផ្ទាល់ដោយគណៈកម្មការគ្រប់គ្រង ដែលមានអាណត្តិ៥ឆ្នាំ។ សមាសភាពគណៈកម្មការដឹកនាំមានប្រធាន អនុប្រធាន២រូប ព្រមទាំងសមាជិកគណៈកម្មការ។ ជំនួយមួយរូបត្រូវបានតែងតាំង ពីប្រធានសម្រាប់ជួយការងាររបស់ខ្លួន។

### ក . ប្រធានបណ្តាញ

- ដឹកនាំការរៀបចំផែនការសកម្មភាពគ្រប់គ្រងរយៈពេល៣ឆ្នាំ
- ដឹកនាំការអនុវត្តន៍ផែនការ ការត្រួតពិនិត្យ និងការវាយតំលៃ
- ប្រមូលព័ត៌មានពីសមាជិកបណ្តាញសហគមន៍នេសាទ មកធ្វើជាផែនការរួម
- រៀបចំផែនការសកម្មភាពប្រចាំឆមាស ឬប្រចាំឆ្នាំ
- ផ្តល់យោបល់លើផែនការរបស់សហគមន៍នេសាទជាសមាជិកបណ្តាញ
- ទទួល និងចែករំលែកបន្តនូវព័ត៌មានជូនដល់សមាជិកបណ្តាញនៅតាមសហគមន៍នេសាទ
- ទំនាក់ទំនងជាមួយអង្គភាពពាក់ព័ន្ធ ឬអង្គការដៃគូពាក់ព័ន្ធ
- ទំនាក់ទំនងរកការគាំទ្រធនធានពីប្រភពខាងក្រៅ
- សម្របសម្រួលដោះស្រាយទំនាស់ដែលកើតមានឡើងក្នុងសហគមន៍នេសាទ
- សម្របសម្រួលរៀបចំបោះឆ្នោតជ្រើសរើសបណ្តាញសហគមន៍នេសាទសម្រាប់អាណត្តិបន្ទាប់។

### ខ. អនុប្រធាន

- បំពេញតួនាទី និងភារៈ កិច្ចពេលប្រធានអវត្តមានតាមការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ
- ជំនួយការផ្ទាល់របស់ប្រធានលើសំណើ លើគោលការណ៍ផ្សេងៗអោយពិនិត្យ និងសម្រេច
- ជួយការងារប្រធានក្នុងការធ្វើកំណត់ហេតុរបាយការណ៍
- គ្រប់គ្រងឯកសារ និងជួយលើការទំនាក់ទំនងក្នុង និងក្រៅសហគមន៍
- ជួយការងារផ្សេងទៀតដែលប្រធានប្រគល់ជូន។

### គ. ជំនួយការ

- ជួយចាត់ចែង និងរៀបចំព័ត៌មានសម្រាប់កិច្ចប្រជុំ
- រៀបចំកំណត់ហេតុសម្រាប់គ្រប់អង្គប្រជុំរបស់បណ្តាញសហគមន៍នេសាទ
- រៀបចំឯកសារ ឬព័ត៌មានសម្រាប់បណ្តាញក្នុងការជួបជាមួយអង្គភាព ឬអ្នកពាក់ព័ន្ធនានា
- ថែរក្សា និងទុកដាក់ឯកសារ ឬព័ត៌មាន និងបញ្ជីការនានារបស់បណ្តាញសហគមន៍នេសាទ
- ជួយប្រធាន អនុប្រធានក្នុងការរៀបចំត្រៀមសម្រាប់ការបោះឆ្នោតជ្រើសរើសបណ្តាញសហគមន៍នេសាទថ្មី សម្រាប់អាណត្តិបន្ទាប់
- កាន់សាច់ប្រាក់ និងគ្រប់គ្រងបញ្ជីចំណូល និងចំណាយ
- ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ។

## ៤. ផែនការសកម្មភាពបណ្តាញសហគមន៍នេសាទ

### ៤.១ ផែនការសកម្មភាពបណ្តាញសហគមន៍នេសាទសម្រាប់ ៣ឆ្នាំ (២០២៥-២០២៨)

| សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | ប្រភពថវិកា | ថ្ងៃ ខែ ឆ្នាំ | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ | |
| **១. លើកកម្ពស់ភាពជាតំណាងនៃសហគមន៍នេសាទ ក្នុងការចងក្រងទិន្នន័យ និងប្រមូលព័ត៌មាន** | | | | | | |
| ១.១ សមាជិកគណៈកម្មការបណ្តាញសហគមន៍នេសាទចុះប្រមូលព័ត៌មាន និងចងក្រងទិន្នន័យរបស់សហគមន៍នេសាទ | ថ្លៃអាហារ និងការធ្វើដំណើរ<br>៩ស.ន x ២ដង x ១៥ដុល្លារ x ៣ឆ្នាំ | ៨១០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ១.២ ការប្រជុំពិភាក្សាចងក្រងទិន្នន័យ និងរៀបចំរបាយការណ៍របស់សមាជិកបណ្តាញសហគមន៍នេសាទ ដែលបាន៖<br>- ទទួលរបាយការណ៍លទ្ធផលការងាររបស់សហគមន៍នេសាទ<br>- ប្រមូលព័ត៌មាន បញ្ហាប្រឈម កង្វល់ និងតម្រូវការសហគមន៍នេសាទ | ថ្លៃអាហារ និងការធ្វើដំណើរ<br>៩ស.ន x ២ដង x ១៥ដុល្លារ x ៣ឆ្នាំ | ៨១០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| **២. ការចែករំលែកព័ត៌មាន និងផ្សព្វផ្សាយពីបទដ្ឋានគតិយុត្តិផ្សេងៗ** | | | | | | |
| ២.១ ប្រជុំគណៈកម្មការបណ្តាញសហគមន៍នេសាទផ្សព្វផ្សាយលទ្ធផល និងបទពិសោធន៍ការងារ ដែលទទួលបានជោគជ័យ និងគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ | ថ្លៃអាហារ និងការធ្វើដំណើរ<br>៩ស.ន x ២ដង x ១៥ដុល្លារ x ៣ឆ្នាំ | ៨១០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ២.២ ចុះប្រជុំផ្សព្វផ្សាយលទ្ធផល និងបទពិសោធន៍ការងារ ដែលទទួលបានជោគជ័យ និងគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ | អាហារសម្រន់ និងថតចំលងឯកសារ<br>៩ស.ន x ២ដង x ២០ដុល្លារ x ៣ឆ្នាំ<br>អ្នកចូលរួមប្រមាណ១៣នាក់ | ១ ០៨០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ២.៣ ចូលរួមកិច្ចប្រជុំជាមួយអាជ្ញាធរ ដើម្បីទទួលយកគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ | ថ្លៃអាហារ និងការធ្វើដំណើរ<br>៩ស.ន x ២ដង x ១៥ដុល្លារ x ៣ឆ្នាំ | ៨១០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| **៣. ការពង្រឹងកិច្ចសហការ និងការគ្រប់គ្រងសម្រាប់គណៈកម្មការ និងសហគមន៍ជាសមាជិកបណ្តាញ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ** | | | | | | |
| ៣.១ ប្រជុំគណៈកម្មការបណ្តាញសហគមន៍នេសាទ ប្រចាំត្រីមាស | ៤ដងx៣ឆ្នាំx៣៣០ដុល្លារ | ៣ ៩៦០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ៣.២ ចូលរួមប្រជុំប្រចាំត្រីមាសជាមួយអាជ្ញាធរ (ស្រុក/ខេត្ត) ក្នុងការពាំនាំលទ្ធផលការងារ បញ្ហាប្រឈម កង្វល់ និងតម្រូវការផ្សេងៗ | ថ្លៃអាហារ ស្នាក់នៅនិងការដំណើរ ២នាក់ x ៤ដង x ៣៥ដុល្លារ x ៣ឆ្នាំ | ១ ១២០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ៣.៣ ចូលរួមកិច្ចប្រជុំវិសាមញ្ញ | ថ្លៃអាហារ ស្នាក់នៅនិងការដំណើរ ២នាក់ x ៦ដង x ៣៥ដុល្លារ x ៣ឆ្នាំ | ១ ២៦០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ៣.៤ ពង្រីកវិសាលភាពសមាជិកបណ្តាញសហគមន៍នេសាទថ្នាក់ខេត្ត តាមរយៈកិច្ចប្រជុំពិភាក្សាបញ្ចូលសមាជិកបណ្តាញថ្នាក់ខេត្ត | ការប៉ាន់ប្រមាណរួម | ១ ០០០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ<br>- ដៃគូផ្សេងៗ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ៣. ៥ ពង្រីកកិច្ចសហការរវាងបណ្តាញសហគមន៍នេសាទ និងបណ្តាញសហគមន៍មូលដ្ឋានផ្សេងៗ | ការប៉ាន់ប្រមាណរួម | ២ ៥០០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ<br>- ដៃគូផ្សេងៗ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ៣. ៦ ចូលរួមនៅក្នុងការគ្រប់គ្រង ការពារ និងអភិរក្សធនធានជលផល ដែលសហគមន៍នេសាទជាសមាជិកបណ្តាញអញ្ជើញឱ្យចូលរួម | ការប៉ាន់ប្រមាណរួម | ១ ៥០០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ<br>- ដៃគូផ្សេងៗ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| **៤. លើកកម្ពស់ទំនាក់ទំនង និងកៀរគរធនធាន និងមធ្យោបាយផ្សេងៗ សម្រាប់គណៈកម្មការបណ្តាញ និងសមាជិកបណ្តាញសហគមន៍នេសាទ** | | | | | | |
| ៤.១ ការទំនាក់ទំនងជាមួយអាជ្ញាធរ (ស្រុក/ខេត្ត) និងអង្គភាពពាក់ព័ន្ធ អង្គការដៃគូ និងសប្បុរសជន ស្វែងរកគាំទ្រផែនការសកម្មភាពបណ្តាញសហគមន៍នេសាទ | ការប៉ាន់ប្រមាណរួម | ៣០០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤.២ ផ្សព្វផ្សាយផែនការបណ្តាញសហគមន៍នេសាទ និងផែនការគ្រប់គ្រងសហគមន៍នេសាទដែលជាសមាជិកបណ្តាញសហគមន៍នេសាទ | ធ្វើសមាហរណកម្មផែនការបណ្តាញសហគមន៍នេសាទចូលក្នុងផែនការវិនិយោគ៣រំកិលរបស់ស្រុក<br>ថ្លៃអាហារ ស្នាក់នៅនិងការដំណើរ<br>២នាក់ x ១ដង x ៣៥ដុល្លារ x ៣ថ្ងៃ | ២១០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| | ធ្វើសមាហរណកម្មផែនការបណ្តាញសហគមន៍នេសាទចូលក្នុងផែនការវិនិយោគ៥ឆ្នាំរបស់ស្រុក<br>ថ្លៃអាហារ ស្នាក់នៅនិងការដំណើរ<br>២នាក់ x ១ដង x ៣៥ដុល្លារ x ៣ថ្ងៃ | ២១០ | | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| | ចូលរួមរៀបចំផែនការប្រចាំឆ្នាំរបស់ស្រុក<br>ថ្លៃអាហារ ស្នាក់នៅនិងការដំណើរ<br>២នាក់ x ៣ដង x ៣៥ដុល្លារ x ៣ថ្ងៃ | ៦៣០ | | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ៤.៣ ប្រជុំរៀបចំគម្រោងសំណើសុំថវិកា ពីប្រភពមូលនិធិផ្សេងៗ | ការប៉ាន់ប្រមាណរួម | ៧៥០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ<br>- ដៃគូផ្សេងៗ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| **៥. ការពង្រឹងសមត្ថភាព និងការបណ្តុះបណ្តាល** | | | | | | |
| ៥.១ ការប្រមូលទិន្នន័យ  និងការសរសេររបាយការណ៍ | ការប៉ាន់ប្រមាណរួម | ៧៥០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ<br>- ដៃគូផ្សេងៗ | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| ៥.២ ជំនាញភាពជាអ្នកដឹកនាំ ទំនាក់ទំនង និងការសម្របសម្រួល | ការប៉ាន់ប្រមាណរួម | ៧៥០ | | | | |
| ៥.៣ គម្រោងសំណើ និងគ្រប់គ្រងថវិកា | ការប៉ាន់ប្រមាណរួម | ៧៥០ | | | | |
| ៥.៤ ការប្រើប្រាស់ឧបករណ៍ស្មាតផូលសម្រាប់ល្បាត | ការប៉ាន់ប្រមាណរួម | ៧៥០ | | | | |
| ៥.៥ ទស្សនៈកិច្ចសិក្សា និងចែករំលែកបទពិសោធន៍ | ថ្លៃអាហារ ស្នាក់នៅនិងការដំណើរ<br>៩នាក់ x ៣ដង x ៩៥ដុល្លារ x៣ថ្ងៃ | ៧ ៦៩៥ | | កក្កដា ២០២៥ | មិថុនា ២០២៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| **៦. តម្រូវការមធ្យោបាយ និងសម្ភារផ្សេងៗ សម្រាប់គណៈកម្មការបណ្ដាញ** | | | | | | |
| ៦.១ ឧបករណ៍សម្រាប់ទំនាក់ទំនង (ទូរស័ព្ទ និងអាយកូម) សម្រាប់ចុះយកព័ត៌មាន | ទិញទូរស័ព្ទ ២គ្រឿង x ២១០ដុល្លារ | ៤២០ | - អង្គការ<br>- សហគមន៍<br>- អាជ្ញាធរ<br>- ដៃគូផ្សេងៗ<br>- សប្បុរសជន | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| | ទិញអាកុម ៩គ្រឿង x ៧០ដុល្លារ | ៦៣០ | | | | |
| ៦.២ ម៉ូតូ និងមួកសុវត្ថិភាព | ទិញម៉ូតូម៉ាក់ហុងដាសង់ ២គ្រឿង | ៤ ៥០០ | | | | |
| ៦.៣ ទូកល្បាត (អូប័រម៉ាស៊ីនកំលាំង៤០សេះ) | ទិញទូកអូប័រ១គ្រឿង | ៦ ៥០០ | | | | |
| ៦.៤ សម្ភារចូលរួមល្បាត | - អាវភ្លៀង<br>- ពិល<br>- សម្ភារៈពេទ្យសង្គ្រោះបឋម<br>- មួក | ៣០០ | | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| | កាមេរ៉ា២គ្រឿង | ៩០០ | | | | |
| | សំលៀកបំពាក់ ៩នាក់ | ៤៥០ | | | | |
| ៦.៥ សម្ភារការិយាល័យ | កុំព្យូទ័រ | ៥៥០ | | កក្កដា ២០២៥ | មិថុនា ២០២៨ | |
| | ម៉ាស៊ីនកូពី | ១៥០ | | | | |
| | ទិញក្រដាស ប៊ិច ទូដាក់ឯកសា | ៣០០ | | | | |
| **សរុបថវិកា** | | $ **៤៣ ១៥៥** | | | | |

## ៤. ២ ផែនការសកម្មភាពបណ្តាញសហគមន៍នេសាទប្រចាំឆ្នាំ (២០២៥-២០២៦)

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២៥ | | | | | | ២០២៦ | | | | | | | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **១. លើកកម្ពស់ភាពជាតំណាងនៃសហគមន៍នេសាទ ក្នុងការចងក្រងទិន្នន័យ និងប្រមូលព័ត៌មានផ្សេងៗ** | | | | | | | | | | | | | | | | | | |
| ១.១ សមាជិកគណៈកម្មការបណ្តាញសហគមន៍នេសាទចុះប្រមូលព័ត៌មាន និងចងក្រងទិន្នន័យរបស់សហគមន៍នេសាទ | | | | | X | | | | | | x | | | | | x | | |
| ១.២ ការប្រជុំពិភាក្សាចងក្រងទិន្នន័យ និងរៀបចំរបាយការណ៍របស់សមាជិកបណ្តាញសហគមន៍នេសាទ ដែលបាន៖<br>- ទទួលរបាយការណ៍លទ្ធផលការងាររបស់សហគមន៍នេសាទ<br>- ប្រមូលព័ត៌មាន បញ្ហាប្រឈម កង្វល់ និងតម្រូវការសហគមន៍ | | | | | X | | | | | | x | | | | | x | | |
| **២. ការចែករំលែកព័ត៌មាន និងផ្សព្វផ្សាយពីបទដ្ឋានគតិយុត្តិផ្សេងៗ** | | | | | | | | | | | | | | | | | | |
| ២.១ ប្រជុំគណៈកម្មការបណ្តាញសហគមន៍នេសាទផ្សព្វផ្សាយលទ្ធផល និងបទពិសោធន៍ការងារ ដែលទទួលបានជោគជ័យ និងគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ | | | | | | X | | | | | | | x | | | | | x |
| ២.២ ចុះប្រជុំផ្សព្វផ្សាយលទ្ធផល និងបទពិសោធន៍ការងារ ដែលទទួលបានជោគជ័យ និងគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ | | | | | | X | | | | | | | x | | | | | x |
| ២.៣ ចូលរួមកិច្ចប្រជុំជាមួយអាជ្ញាធរ ដើម្បីទទួលយកគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ | | | | | | | | | | | | | | | | | | |
| **៣. ការពង្រឹងកិច្ចសហការ និងការគ្រប់គ្រងសម្រាប់គណៈកម្មការ និងសហគមន៍ជាសមាជិកបណ្តាញ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ** | | | | | | | | | | | | | | | | | | |
| ៣.១ ប្រជុំគណៈកម្មការបណ្តាញសហគមន៍នេសាទ ប្រចាំត្រីមាស | | | x | | | X | | | x | | | x | | | x | | | x |
| ៣.២ ចូលរួមប្រជុំប្រចាំត្រីមាសជាមួយអាជ្ញាធរ (ស្រុក/ខេត្ត) ក្នុងការពាំនាំលទ្ធផលការងារ បញ្ហាប្រឈម កង្វល់ និងតម្រូវការផ្សេងៗ | | | x | | | X | | | x | | | x | | | x | | | x |
| ៣.៣ ចូលរួមកិច្ចប្រជុំវិសាមញ្ញ | | | | | | | | | | | | | | | | | | |
| ៣.៤ ពង្រីកវិសាលភាពសមាជិកបណ្តាញសហគមន៍នេសាទថ្នាក់ខេត្តតាមរយៈកិច្ចប្រជុំពិភាក្សាបញ្ចូលសមាជិកបណ្តាញថ្នាក់ខេត្ត | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣. ៥ ពង្រឹកកិច្ចសហការរវាងបណ្តាញសហគមន៍នេសាទនិងបណ្តាញសហគមន៍មូលដ្ឋានផ្សេងៗ | | | | | | | | | | | | | | | | | | |
| ៣. ៦ ចូលរួមនៅក្នុងការគ្រប់គ្រង ការពារ និងអភិរក្សធនធានធម្មជាតិដែលសហគមន៍នេសាទជាសមាជិកបណ្តាញអញ្ជើញឱ្យចូលរួម | | | | | | | | | | | | | | | | | | |
| **៤. លើកកម្ពស់ទំនាក់ទំនង និងកៀរគរធនធាន និងមធ្យោបាយផ្សេងៗ សម្រាប់គណៈកម្មការបណ្តាញ និងសមាជិកបណ្តាញសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | |
| ៤.១ ការទំនាក់ទំនងជាមួយអាជ្ញាធរ (ស្រុក/ខេត្ត) និងអង្គភាពពាក់ព័ន្ធ អង្គការដៃគូ និងសប្បុរសជន ស្វែងរកគាំទ្រផែនការសកម្មភាពបណ្តាញសហគមន៍នេសាទ | | | x | | | X | | | x | | | x | | | x | | | x |
| ៤.២ ផ្សព្វផ្សាយផែនការបណ្តាញសហគមន៍នេសាទ និងផែនការគ្រប់គ្រងសហគមន៍នេសាទដែលជាសមាជិកបណ្តាញសហគមន៍ | | | x | | | X | | | x | | | x | | | x | | | x |
| ៤.៣ ប្រជុំរៀបចំគម្រោងសំណើស្នើសុំថវិកា ពីប្រភពមូលនិធិផ្សេងៗ | | | | | | | x | x | | | x | x | | | | | | |
| **៥. ការកសាងកសាងសមត្ថភាព និងការបណ្តុះបណ្តាល** | | | | | | | | | | | | | | | | | | |
| ៥.១ ការប្រមូលទិន្នន័យ និងការសរសេររបាយការណ៍ | | | x | | | | | | | | | | | | | | | |
| ៥.២ ជំនាញភាពជាអ្នកដឹកនាំ ទំនាក់ទំនង និងការសម្របសម្រួល | | | | | | X | | | | | | | | | | | | |
| ៥.៣ គម្រោងសំណើ និងគ្រប់គ្រងថវិកា | | | | | | | | | x | | | | | | | | | |
| ៥.៤ ការប្រើប្រាស់ឧបករណ៍ស្មាតផូលសម្រាប់ល្បាត | | | | | | | | | | | | x | | | | | | |
| ៥.៥ ទស្សនៈកិច្ចសិក្សា និងចែករំលែកបទពិសោធន៍ | | | | | | X | | | | | | | | | | | | x |
| **៦. តម្រូវការមធ្យោបាយ និងសម្ភារផ្សេងៗ សម្រាប់គណៈកម្មការបណ្តាញ** | | | | | | | | | | | | | | | | | | |
| ៦.១ ឧបករណ៍សម្រាប់ទំនាក់ទំនង (ទូរស័ព្ទ និងអាយកូម) សម្រាប់ចុះយកព័ត៌មាន | | | | | | | | | | | | | | | | | | |
| ៦.២ ម៉ូតូ និងមួកសុវត្ថិភាព | | | | | | | | | | | | | | | | | | |
| ៦.៣ ទូកល្បាត (អ៊ូប័រ ម៉ាស៊ីនកំលាំង៤០សេះ) | | | | | | | | | | | | | | | | | | |
| ៦.៤ សម្ភារចូលរួមល្បាត | | | | | | | | | | | | | | | | | | |
| ៦.៥ សម្ភារការិយាល័យ | | | | | | | | | | | | | | | | | | |

## ៤. ២ ផែនការសកម្មភាពបណ្ដាញសហគមន៍នេសាទប្រចាំឆ្នាំ (២០២៧-២០២៨)

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២៧ | | | | | | | | | | | | ២០២៨ | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| **១. លើកកម្ពស់ភាពជាតំណាងនៃសហគមន៍នេសាទ ក្នុងការចងក្រងទិន្នន័យ និងប្រមូលព័ត៌មានផ្សេងៗ** | | | | | | | | | | | | | | | | | | |
| ១.១ សមាជិកគណៈកម្មការបណ្ដាញសហគមន៍នេសាទចុះប្រមូលព័ត៌មាន និងចងក្រងទិន្នន័យរបស់សហគមន៍នេសាទ | | | | | x | | | | | | x | | | | | | x | |
| ១.២ ការប្រជុំប្រមូលព័ត៌មាន និងចងក្រងទិន្នន័យពីសមាជិកបណ្ដាញសហគមន៍នេសាទ<br>- ទទួលរបាយការណ៍លទ្ធផលការងាររបស់សហគមន៍នេសាទ<br>- ប្រមូលព័ត៌មាន បញ្ហាប្រឈម កង្វល់ និងតម្រូវការសហគមន៍ | | | | | x | | | | | | x | | | | | | x | |
| **២. ការចែករំលែកព័ត៌មាន និងផ្សព្វផ្សាយពីបទដ្ឋានគតិយុត្តិផ្សេងៗ** | | | | | | | | | | | | | | | | | | |
| ២.១ ប្រជុំគណៈកម្មការបណ្ដាញសហគមន៍នេសាទផ្សព្វផ្សាយលទ្ធផល និងបទពិសោធន៍ការងារ ដែលទទួលបានជោគជ័យ និងគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ | | | | | | | x | | | | | x | | | | | | x |
| ២.២ ចុះប្រជុំផ្សព្វផ្សាយលទ្ធផល និងបទពិសោធន៍ការងារ ដែលទទួលបានជោគជ័យ និងគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ | | | | | | | x | | | | | x | | | | | | x |
| ២.៣ ចូលរួមកិច្ចប្រជុំជាមួយអាជ្ញាធរ ដើម្បីទទួលយកគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ | | | | | | | | | | | | | | | | | | |
| **៣. ការពង្រឹងកិច្ចសហការ និងការគ្រប់គ្រងសម្រាប់គណៈកម្មការ និងសហគមន៍ជាសមាជិកបណ្ដាញ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ** | | | | | | | | | | | | | | | | | | |
| ៣.១ ប្រជុំគណៈកម្មការបណ្ដាញសហគមន៍នេសាទ ប្រចាំត្រីមាស | | | x | | | X | | | x | | | x | | | x | | | x |
| ៣.២ ចូលរួមប្រជុំប្រចាំត្រីមាសជាមួយអាជ្ញាធរ (ស្រុក/ខេត្ត) ក្នុងការពាំនាំលទ្ធផលការងារ បញ្ហាប្រឈម កង្វល់ និងតម្រូវការផ្សេងៗ | | | x | | | X | | | x | | | x | | | x | | | x |
| ៣.៣ ចូលរួមកិច្ចប្រជុំវិសាមញ្ញ | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៤ ពង្រីកវិសាលភាពសមាជិកបណ្ដាញសហគមន៍នេសាទថ្នាក់ខេត្ត តាមរយៈកិច្ចប្រជុំពិភាក្សាបញ្ចូលសមាជិកបណ្ដាញថ្នាក់ខេត្ត | | | | | | | | | | | | | | | | | | |
| ៣. ៥ ពង្រីកកិច្ចសហការរវាងបណ្ដាញសហគមន៍នេសាទនិង បណ្ដាញសហគមន៍មូលដ្ឋានផ្សេងៗ | | | | | | | | | | | | | | | | | | |
| ៣. ៦ ចូលរួមនៅក្នុងការគ្រប់គ្រង ការពារ អភិរក្សធនធានធម្មជាតិ ការដាំស្តារ និង ការឆ្លើយតបការប្រែប្រួលអាកាសធាតុ ដែលសហគមន៍នេសាទជាសមាជិកបណ្ដាញអញ្ជើញឱ្យចូលរួម | | | | | | | | | | | | | | | | | | |
| **៤. លើកកម្ពស់ទំនាក់ទំនង និងកៀរគរធនធាន និងមធ្យោបាយផ្សេងៗ សម្រាប់គណៈកម្មការបណ្ដាញ និងសមាជិកបណ្ដាញសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | |
| ៤.១ ការទំនាក់ទំនងជាមួយអាជ្ញាធរ (ស្រុក/ខេត្ត) និងអង្គភាពពាក់ព័ន្ធ អង្គការដៃគូ និងសប្បុរសជន ស្វែងរកការគាំទ្រផែនការសកម្មភាពបណ្ដាញសហគមន៍នេសាទ | | | x | | | X | | | x | | | x | | | x | | | x |
| ៤.២ ផ្សព្វផ្សាយផែនការបណ្ដាញសហគមន៍នេសាទ និងផែនការគ្រប់គ្រងសហគមន៍នេសាទដែលជាសមាជិកបណ្ដាញសហគមន៍ | | | x | | | X | | | x | | | x | | | x | | | x |
| ៤.៣ ប្រជុំរៀបចំគម្រោងសំណើស្នើសុំថវិកា ពីប្រភពមូលនិធិផ្សេងៗ | x | x | | | x | X | | | | | | x | x | | | | | |
| **៥. ការកសាងកសាងសមត្ថភាព និងការបណ្តុះបណ្តាល** | | | | | | | | | | | | | | | | | | |
| ៥.១ ការប្រមូលទិន្នន័យ និងការសរសេររបាយការណ៍ | | | x | | | | | | | | | | | | | | | |
| ៥.២ ជំនាញភាពជាអ្នកដឹកនាំ ទំនាក់ទំនង និងការសម្របសម្រួល | | | | | | X | | | | | | | | | | | | |
| ៥.៣ គម្រោងសំណើ និងគ្រប់គ្រងថវិកា | | | | | | | | | x | | | | | | | | | |
| ៥.៤ ការប្រើប្រាស់ឧបករណ៍ស្មាតផូលសម្រាប់ល្បាត | | | | | | | | | | | | x | | | | | | |
| ៥.៥ ទស្សនៈកិច្ចសិក្សា និងចែករំលែកបទពិសោធន៍ | | x | | | | | | | | | | | x | | | | | |
| **៦. តម្រូវការមធ្យោបាយ និងសម្ភារផ្សេងៗ សម្រាប់គណៈកម្មការបណ្ដាញ** | | | | | | | | | | | | | | | | | | |
| ៦.១ ឧបករណ៍សម្រាប់ទំនាក់ទំនង (ទូរស័ព្ទ និងអាយកូម) សម្រាប់ចុះយកព័ត៌មាន | | | | | | | | | | | | | | | | | | |
| ៦.២ ម៉ូតូ និងមួកសុវត្ថិភាព | | | | | | | | | | | | | | | | | | |
| ៦.៣ ទូកល្បាត (អូប័រ ម៉ាស៊ីនកំលាំង៤០សេះ) | | | | | | | | | | | | | | | | | | |
| ៦.៤ សម្ភារចូលរួមល្បាត | | | | | | | | | | | | | | | | | | |
| ៦.៥ សម្ភារការិយាល័យ | | | | | | | | | | | | | | | | | | |

## ៥. ផែនការគៀរគរធនធាន និងថវិកា

លើកកម្ពស់កិច្ចសហការ និងការផ្សព្វផ្សាយពីគម្រោងសកម្មភាព ផែនការ និងគំនិតផ្តួចផ្តើមគម្រោងសំណើផ្សេងៗ សម្រាប់បណ្តាញ និងសហគមន៍ជាសមាជិកបណ្តាញ ក្នុងការគៀរគរធនធានផ្សេងៗ ដើម្បីការអនុវត្តផែនការ និងជាប្រយោជន៍សម្រាប់សហគមន៍នេសាទ។ ប្រភពធនធានដែលជាសក្តានុពលរួមមាន៖

- ភាគទានរបស់សហគមន៍នេសាទជាសមាជិកបណ្តាញ
- អំណោយពីសប្បុរសជន
- ថវិកាពីរាជរដ្ឋាភិបាល (មូលនិធិអភិវឌ្ឍន៍នៅតាមមូលដ្ឋាន)
- អង្គការជាតិ និងអង្គការអន្តរជាតិ និងដៃគូសហការ និងភ្នាក់ងារអភិវឌ្ឍន៍

## ៦. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ នឹងត្រូវបានរៀបចំជារបាយការណ៍ សម្រាប់បណ្តាញ ហើយត្រូវបានធ្វើឡើងជាប្រចាំ តាមរយៈកិច្ចប្រជុំត្រីមាស និងជាពិសេសកិច្ចប្រជុំប្រចាំឆ្នាំ ក្នុងការឆ្លុះបញ្ចាំងពីសមិទ្ធិផល បញ្ហាប្រឈម មេរៀនជាបទពិសោធន៍ ការងារបន្ត និងសំណូមពរផ្សេងៗ សម្រាប់ការងារបណ្តាញ។ ការឆ្លុះបញ្ចាំងប្រចាំឆ្នាំ ដែលត្រូវបានសម្របសម្រួលពីបណ្តាញ ដោយមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរ និងភាគីពាក់ព័ន្ធ។ លទ្ធផលពីការចែករំលែក និងឆ្លុះបញ្ចាំង ត្រូវចងក្រងជាឯកសារ ឬរបាយការណ៍សម្រាប់ងាយស្រួលប្រើប្រាស់ និងចែករំលែក ដើម្បីធ្វើឲ្យការអនុវត្តកាន់តែប្រសើរឡើង និងដើម្បីអភិវឌ្ឍផែនការអនាគត។